Australian Mekong Resource Centre

# ព្រឹត្តិបត្រសង្ខេបទន្លេមេគង្គ លេខ10 ខែវិច្ឆិកា ឆ្នាំ២០០៨

## មុខងារអភិបាលនៃ MRC ចំពោះទំនប់វារីអគ្គីសនីតាមដងទន្លេមេគង្គ

- លើកផែនការឡើងវិញដើម្បីទប់ទំនប់តាមដងទន្លេមេគង្គ ការផ្តោតការយកចិត្តទុកដាក់លើ MRC ក្នុងនាមជាស្ថាប័នអភិបាល
- មានការយល់ឃើញ និងការសង្ឃឹមទុកខុសៗគ្នានៃមុខងាររបស់ MRC ក្នុងចំណោមអ្នកផ្តល់ជំនួយ សង្គមស៊ីវិល និងរដ្ឋាភិបាល
- អត្ថបទជាច្រើននៃកិច្ចព្រមព្រៀងឆ្នាំ១៩៩៥ គឺដាក់ការទទួលខុសត្រូវលើ MRC ទាក់ទងនឹងទំនប់តាមដងទន្លេ
- MRC មានភារកិច្ចក្នុងការគ្រប់គ្រងទន្លេដើម្បីប្រើប្រាស់ប្រកបដោយនិរន្តភាព និងសមភាព
- MRC គ្មានអំណាចលើប្រទេសជាសមាជិកដែលមានអធិបតេយ្យភាពទេ
- ក្នុងលក្ខន្តិក: MRC គឺមិនទទួលយកគណនេយ្យភាពពីសារធារណ:ដោយផ្ទាល់ទេ
- ឥឡូវនេះ MRC កំពុងពាក់ព័ន្ធនឹងសកម្មភាពគន្លឹះមួយចំនួនទាក់ទងនឹងទំនប់តាមដងទន្លេ ៖
    - វាយតម្លៃលើអាងទន្លេទាំងមូល
    - ផ្តល់ការណែនាំលើគម្រោងមួយៗ ទៅតាមសំណើរបស់ប្រទេសដែលជាសមាជិក
    - អនុវត្តនីតិវិធីជូនព័ត៌មាន ការប្រឹក្សា និងកិច្ចព្រមព្រៀងដំបូងៗ
    - សម្របសម្រួលកិច្ចពិភាក្សា
- សកម្មភាពនីមួយៗនេះ នាំមកនូវបញ្ហា និងសំណួរសំខាន់ៗជាច្រើន

ព្រឹត្តិបត្រសង្ខេបនេះ ពិនិត្យមើលលើមុខងារ ការទទួលខុសត្រូវ និងភារកិច្ចរបស់គណៈកម្មការទន្លេមេគង្គ (MRC) ដែលមានចែងក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥[1] ដែលមានពាក់ព័ន្ធនឹងនីតិវិធី ផែនការ និងកម្មវិធីផ្សេងៗ។ ព្រឹត្តិបត្រនេះ គឺខិតខំប្រឹងប្រែងបញ្ជាក់ពីការរំពឹងទុក និងបកស្រាយនៃមុខងាររបស់ MRC ចំពោះទំនប់ដែលបានស្នើសុំនៅតាមដងទន្លេមេគង្គ។

ការលើកផែនការឡើងវិញដើម្បីសង់ទំនប់តាមដងទន្លេ បាននាំមកនូវការយកចិត្តទុកដាក់លើមុខងារអភិបាលរបស់ MRC ក្នុងនាមជាអង្គការទទួលបន្ទុកក្នុងអាងទន្លេអន្តរជាតិដែលត្រូវបានទទួលការងារក្នុងការធានាឲ្យបាននូវការប្រើប្រាស់ និងគ្រប់គ្រងលើធនធានទឹក និងធនធានពាក់ព័ន្ធផ្សេងទៀតនៃអាងទន្លេមេគង្គក្រោម (LMB)។ អ្នកទទួលបន្ទុកមកពីប្រទេសជាសមាជិក MRC លេខាធិការ អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិលទាំងអស់គឺនៅតែទាញយកកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ មកធ្វើជាការអះអាងអំពីអ្វីដែល MRC គួរតែធ្វើ និងមិនគួរធ្វើ និងថាតើប្រភេទនៃអង្គការអាងទន្លេគួរតែបែបណា និងមិនគួរបែបណា។

ខណៈដែលសំណួរជាច្រើនចោទសួរអំពីមុខងាររបស់ MRC ត្រូវបានលើកឡើងតាំងពីបង្កើតសំណើដែលស្នើឡើង ដើម្បីទប់ទំនប់តាមដងទន្លេ គឺបានឲ្យសញ្ញាយ៉ាងជាក់ច្បាស់ចំពោះមុខងាររបស់ MRC។ របៀបដែល MRC នឹងដោះស្រាយចំពោះកង្វល់សំខាន់ៗ និងធ្វើតុល្យភាពលើអត្ថប្រយោជន៍ផ្សេងៗនៅអាងទន្លេ នឹងលាតត្រដាងពីការយល់ឃើញចំពោះ MRC ក្នុងចំណោមប្រទេសជាសមាជិក អ្នកផ្តល់ជំនួយ និងប្រជាជនដែលរស់នៅតាមតំបន់អាងទន្លេទាំងមូល។




Under the Mekong Agreement, the MRC has a three-tiered institutional structure: Council (comprising members at ministerial or cabinet level); Joint Committee (heads of departments or higher); and Secretariat (responsible for day to day administration). Based on: www.mrcmekong.org

## ការទទួលខុសត្រូវ និងភារកិច្ចរបស់ MRC ពាក់ព័ន្ធនឹងទំនប់តាមដងទន្លេផ្អែកលើកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ និងនីតិវិធីដែលពាក់ព័ន្ធ

កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ ដែលចុះហត្ថលេខាដោយរដ្ឋាភិបាលទាំងបួននៅទន្លេមេគង្គក្រោម គឺបានបង្កើតជាស្ថាប័ន MRC ដែលស្ថាប័ននេះ គឺមានសហប្រតិបត្តិការជាអន្តរជាតិ (មាត្រា១១) និងមានផ្តល់ចំណុចសំខាន់ៗសម្រាប់រៀបចំអភិបាលកិច្ចតាមរយៈក្រុមប្រឹក្សា MRC គណៈកម្មការចម្រុះ និងលេខាធិការ (18,24,30)។ កិច្ចព្រមព្រៀង រាយចំណុចសំខាន់ៗស្តីពីគោលការណ៍ និងការប្តេជ្ញាចិត្តក្នុងការសហប្រតិបត្តិការឈានទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងលើ LMB។ អ្វីដែលពាក់ព័ន្ធជាពិសេសចំពោះទំនប់តាមដងទន្លេត្រូវបានរាយដូចខាងក្រោម ៖

- **ការទទួលស្គាល់ពីការប្រើប្រាស់ច្រើនយ៉ាង ៖** កិច្ចព្រមព្រៀងទទួលស្គាល់យ៉ាងជាក់ច្បាស់ថា មានការប្រើប្រាស់ច្រើនយ៉ាង និងមានអ្នកប្រើទឹក និងធនធានផ្សេងទៀតច្រើនក្នុង LMB និងថា ការអភិវឌ្ឍប្រកបដោយនិរន្តរភាពគឺតម្រូវឲ្យមានកិច្ចសហការពីផ្នែកផ្សេងៗ ដើម្បី "អាចប្រើប្រាស់ឲ្យបានច្រើនយ៉ាងជាអតិប្បរមា និងទទួលបានផលប្រយោជន៍ទាំងអស់គ្នាចំពោះប្រទេសតាមអាងទន្លេ និងដើម្បីកាត់បន្ថយផលប៉ះពាល់ឲ្យមានជាអប្បបរមា..." (មាត្រា១)។ បង្កប់ក្នុងមាត្រានេះ គឺថា អន្តរាគមន៍ដែលរៀបផែនការរួចហើយក្នុងផ្នែកណាមួយ (ឧទាហរណ៍ វារីអគ្គីសនី) គឺត្រូវសម្របតាមផ្នែកមួយផ្សេងទៀត (ឧទាហរណ៍ មច្ឆជាតិ)។

- **ផែនការអភិវឌ្ឍក្នុងអាងទន្លេ ៖** ក្នុងមាត្រា២ ចែងថា MRC គួរផ្តោតការចូលរួម និង/ឬគម្រោង និងកម្មវិធីទូទាំងអាងទន្លេទាំងមូល និងថា ការងារនេះគួរធ្វើឡើងតាមរយៈការរៀបចំផែនការអភិវឌ្ឍក្នុងអាងទន្លេ (BDP)។ BDP ជាក្របខ័ណ្ឌដែលក្នុងនេះមាន MRC ជាអ្នកជឹងព្ញ វាយតម្លៃ ស្នើសុំការអភិវឌ្ឍ ជាពិសេសគម្រោង និងកម្មវិធីដែលមានពាក់ព័ន្ធនឹងអាងទន្លេទាំងមូល។ ដោយសារសំណើសងទំនប់តាមដងទន្លេមិនត្រូវបានបញ្ចូលក្នុងការវិភាគសេណារ៉េយ៉ូអភិវឌ្ឍក្នុង BDP ដំណាក់កាលទីមួយ ការវាយតម្លៃលើសក្តានុពលនៃផលប៉ះពាល់គឺត្រូវបានធ្វើឡើងតាម " វិធីសាស្ត្រភ្លាម" ក្នុងដំណាក់កាលទីពីររបស់ BDP[2]។ ប្រសិនបើ BDP គឺនៅតែត្រូវបានគោរពតាម ការធ្វើទំនប់គឺមិនគួរធ្វើឡើងដោយមិនបានយោងលើផែនការនេះទេ។
- **ការទទួលខុសត្រូវចំពោះអេកូឡូស៊ី ៖** មាត្រា៣ និង ៧ មានគូសបញ្ជាក់ពីទំនួលខុសត្រូវរបស់ MRC "ក្នុងការការពារបរិស្ថាន ធនធានធម្មជាតិ ជីវិតជលជាតិ និងលក្ខខ័ណ្ឌ និងតុល្យភាពនៃអាងទន្លេមេគង្គ" រួមមាន "ខិតខំប្រឹងប្រែងក្នុងការជៀសវាង បង្រួមឲ្យបានតូចបំផុត និងបន្ធូរបន្ថយនូវឥទ្ធិពលអាក្រក់ដែលអាចកើតឡើង " អំពីការអភិវឌ្ឍ និងការប្រើប្រាស់ទន្លេ"។ ទង្វើទាំងនេះ រួមមានការទទួលស្គាល់ពីតម្រូវការដែលត្រូវរក្សាឲ្យបាននូវទំហំធារទឹកហូរតាមដងទន្លេមេគង្គព្រោះវាចាំបាច់សម្រាប់ផលិតភាពនៃមច្ឆជាតិ និងបញ្ហាបរិស្ថានសំខាន់ផ្សេងៗទៀត (មាត្រា ៦ និង២៦)។
- **ការប្រើប្រាស់ទឹក ៖** កិច្ចព្រមព្រៀងសម្រាប់ប្រើប្រាស់ទឹកពីដងទន្លេមេគង្គ គឺស្ថិតលើគោលការណ៍ប្រើប្រាស់ប្រកបដោយ "សមស្រប និងសមធម៌" (មាត្រា៥)។ ច្បាប់ដែលច្បាស់លាស់ថាអ្វីដែលថា "សមធម៌" និង "សមស្រប" គឺមិនបានលើកឡើងទេ។ ខណៈដែលបទប្បញ្ញាត្តិក្នុងកិច្ចព្រមព្រៀងធ្វើបដិញ្ញាថា ច្បាប់នឹងត្រូវបានបង្កើតឡើង (មាត្រា២៦ ៥B) ទាំងនេះជាផ្នែកមួយដែលទន់ខ្សោយនាពេលបច្ចុប្បន្ន ចំពោះ "នីតិវិធី" ក្រៅផ្លូវការ។

នីតិវិធីមួយចំនួនត្រូវបានព្រមព្រៀងដោយរដ្ឋាភិបាលសមាជិកទាំង៤ (មើលប្រអប់)។ យ៉ាងណាក៏ដោយ នីតិវិធីទាំងនេះ មិនមែនជាច្បាប់ដែលអាចអនុវត្តបានក្នុងកិច្ចព្រមព្រៀងទេ។ ក្នុងកិច្ចព្រមព្រៀង ភាគីណាមួយក៏ដោយ ក៏មិនអាចពឹងពាក់បានដែរ ប្រសិនបើមានជម្លោះ និងពេលណាមានជម្លោះបង្កដោយទំនប់តាមដងទន្លេ។ MRC គឺគ្មានអំណាចលើប្រទេសណាមួយទេ ពេលដែល MRC ចូលមកកាន់គម្រោងធំណាមួយក្នុងដែន LMB ដូចជាគម្រោងសំណើធ្វើទំនប់តាមដងទន្លេ។

.

**នីតិវិធីរបស់ MRC**

- **នីតិវិធីសម្រាប់ការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន ៖** (ត្រូវបានអនុម័តឆ្នាំ២០០១) ផ្តល់នូវក្របខ័ណ្ឌសម្រាប់ប្រតិបត្តិការណ៍ផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានក្នុងចំណោមប្រទេសជាសមាជិករបស់MRC ទាំងបួន ដោយមានលេខាធិការជាអ្នករៀបចំ និងគ្រប់គ្រងក្នុងប្រព័ន្ធព័ត៌មាន(IS)របស់ MRC ។ ការណែនាំស្តីពី ការរៀបចំ និងការគ្រប់គ្រងរបស់ MRC-IS (ដាក់ឲ្យប្រើប្រាស់កាលពីខែកក្កដា ឆ្នាំ២០០២) ជាគោលការណ៍ប្រតិបត្តិការ និងសកម្មភាពនៃការរៀបចំ និងគ្រប់គ្រងទិន្នន័យ។

- **នីតិវិធីសម្រាប់តាមដានការប្រើប្រាស់ទឹក ៖** (ត្រូវបានអនុម័តឆ្នាំ២០០៣) ផ្តល់នូវក្របខ័ណ្ឌសម្រាប់អនុវត្តការតាមដានការប្រើប្រាស់ទឹកទាំងខាងក្នុង និងខាងក្រៅអាង។

- **នីតិវិធីសម្រាប់ជូនដំណឹង ការប្រឹក្សាយោបល់ និងកិច្ចព្រមព្រៀងដំបូង (PNPCA) ៖** (ត្រូវបានអនុម័តឆ្នាំ ២០០៣) ផ្តល់នូវចំណុចសំខាន់ៗពីដែនកំណត់ គម្រោងពេលវេលា ខ្លឹមសារ ទ្រង់ទ្រាយ យន្តការស្ថាប័នសម្រាប់គ្រប់គ្រង PNPCA។

- **នីតិវិធីសម្រាប់រក្សាលំហូរទឹកក្នុងដងទន្លេ ៖** (ត្រូវបានអនុម័តឆ្នាំ២០០៦) ផ្តល់នូវក្របខ័ណ្ឌសម្រាប់ការណែនាំបច្ចេកទេស ការរៀបចំស្ថាប័ន ទិសដៅ និងព័ត៌មាន ដើម្បីជួយឲ្យ MRC រក្សា និងគ្រប់គ្រងបាននូវលំហូរទឹកក្នុងដងទន្លេមេគង្គ ដូចដែលមានចែងក្នុងមាត្រា៦ និង២៦នៃកិច្ចព្រមព្រៀងទន្លេមេគង្គ។ ការណែនាំបច្ចេកទេស ដែលកំណត់និយមន័យពីលំហូរទឹកដែលអាចទទួលយកបានក្នុងតំបន់ណាមួយនោះ គឺត្រូវតែបង្កើតឡើងបន្ទាប់មកទៀត។ ច្បាប់សម្រាប់រក្សាលំហូរទឹកក្នុងដងទន្លេ ត្រូវបានប្តូរឈ្មោះថាជានីតិវិធីកាលពីកិច្ចប្រជុំក្រុមប្រឹក្សាលើកទី១១ MRC កាលពីខែធ្នូ ឆ្នាំ២០០៤។

នីតិវិធីទាំងឡាយអាចរកបានក្នុង ៖ http://www.mrcmekong.org/programmes/wup.htm

**មុខងាររបស់ MRC ៖ ការរំពឹងទុក និងការបកស្រាយ**

កិច្ចព្រមព្រៀងបានផ្តល់ចំណុចសំខាន់ៗស្តីពីការទទួលខុសត្រូវរបស់ MRC ប៉ុន្តែការពិពណ៌នាអំពីមុខងារ និងអំណាចគឺមិនច្បាស់លាស់ទេ។ ភាពមិនច្បាស់លាស់នេះ ចូលរួមឲ្យមានការបកស្រាយ និងការរំពឹងផ្សេងៗ អំពីមុខងារ និងអំណាចរបស់ MRC ដូចអ្វីដែលបានពោលដោយអ្នកទទួលបន្ទុកផ្សេងៗ ពោលគឺពីអ្នកទាំងនោះជាអ្នកមានពាក់ព័ន្ធ និងមានសកម្មភាពជាមួយ MRC (មើលប្រអប់ខាងក្រោម)។

MRC ជាអង្គការអន្តររដ្ឋាភិបាល ដែលមានគោលដៅយុទ្ធសាស្ត្រ គោលនយោបាយ និងការសម្រេចចិត្តត្រូវបានធ្វើឡើងដោយគណៈកម្មការ និងក្រុមប្រឹក្សាចម្រុះ ហើយលេខាធិការដើរតួជាអ្នកផ្តល់យោបល់។ MRC គ្មានអំណាចលើប្រទេសតាមផ្លូវច្បាប់ទេ ដូច្នេះក្នុងន័យជាផ្លូវការ MRC គឺនៅមានកម្រិត ឬគ្មានអំណាចបទបញ្ជាទេ។ ជំនួសមកវិញ MRC គឺត្រូវបានអូសទាញដោយផលប្រយោជន៍ជាតិរបស់ប្រទេសជាសមាជិកណាមួយ ដែលមានអ្នកតំណាងតាមគណៈកម្មការមេគង្គជាតិ (NMCs)។ ផលប្រយោជន៍ទាំងនេះ គឺហាក់ដូចជាទំនោររកផលប្រយោជន៍សេដ្ឋកិច្ច របស់ប្រទេសណាមួយដែលអាចទាញយកពីទន្លេ ហើយនេះជាអ្វីដែលចម្បងសម្រាប់ប្រទេសជាសមាជិក ចំពោះការយល់ឃើញអំពីមុខងារ និងគោលបំណងនៃការបង្កើត MRC។

**ទស្សនៈវិស័យផ្សេងៗចំពោះមុខងាររបស់ MRC**

*"កិច្ចព្រមព្រៀងឆ្នាំ១៩៩៥ និយាយថា យើងត្រូវមានការអភិវឌ្ឍ។ យើងត្រូវការទំនប់ដើម្បីគ្រប់គ្រងទន្លេ។ BDP ជាគម្រោងអភិវឌ្ឍ មិនមែនជាគម្រោងដាក់បទបញ្ញាទេ"។*

- សមាជិកគណៈកម្មការចម្រុះវៀតណាម ២០០៥[3]

*"នាពេលថ្មីៗនេះ ប្រទេសទាំងឡាយបង្ហាញពីភាពលែងអត់ធ្មត់ចំពោះកម្សោយរបស់MRC ក្នុងការជួយប្រទេសទាំងឡាយឲ្យកំណត់ពីឱកាសសម្រាប់ការអភិវឌ្ឍ និងជួយសម្រួលដល់ការវិនិយោគ"*

- ធនាគារពិភពលោក/ធនាគារអភិវឌ្ឍន៍អាស៊ី ឯកសារសម្រាប់ពិភាក្សា, មិថុនា ២០០៦[4]

*"អ្នកផ្តល់ជំនួយមានការព្រួយបារម្ភ និងមានការផ្តោតអារម្មណ៍កើនឡើងលើ MRC ដោយចាត់ទុកMRC ជាអង្គការសម្រាប់ការវិនិយោគ។ ក្នុងទស្សនៈរបស់យើង MRC គួរតែរក្សា និងពង្រឹងមុខងារទោលនេះ ថាជាអង្គការផ្តល់ចំណេះដឹងពីអាងទន្លេដើម្បីគាំទ្រការសម្រេចចិត្តលើការអភិវឌ្ឍក្នុងអាងទន្លេ "*

- ពំនោលរបស់ក្រុមអ្នកផ្តល់ជំនួយ ខែធ្នូ ២០០៥[5]

*"ដៃគូអភិវឌ្ឍ គឺមានការព្រួយបារម្ភជាពិសេសថា អ្នកពាក់ព័ន្ធសាធារណៈ និងឯកជន មិនត្រូវបានប្រឹក្សាយោបល់ និងថាផលប៉ះពាល់ត្រួតគ្នា នៃទំនប់លើមេធ្លជាតិ និងសុវត្ថិភាពស្បៀង គឺមិនត្រូវបានផ្តល់ការយកចិត្តទុកដាក់គ្រប់គ្រាន់។ ពាក់ព័ន្ធនឹងរឿងនេះ យើងសំណូមពរថា ក្រុមប្រឹក្សា MRC ត្រូវអនុវត្តនូវការផ្តល់ព័ត៌មានស្តីពីរបៀបនៃនីតិវិធីជូនដំណឹង ការប្រឹក្សាមុន និងកិច្ចព្រមព្រៀងមុន។"*

- ពោលដោយក្រុមប្រឹក្សាដៃគូអភិវឌ្ឍន៍ ១៥ វិច្ឆកា ២០០៧[6]

*"មានភស្តុតាងថា ប្រទេសជាសមាជិក គឺសំឡឹងមើលទិន្នផលជាក់ស្តែងដើម្បីធ្វើឲ្យប្រសើរឡើងនូវការយល់ឃើញរបស់ខ្លួនស្តីពីMRC ថាជាអង្គការមួយដែលជួយរៀបផែនការសម្រាប់ការអភិវឌ្ឍក្នុងអាងទន្លេ ឬនិយាយម្យ៉ាងទៀតថា មិនមែនជាអង្គការសម្រាប់សិក្សាបែបវិទ្យាសាស្ត្រនៅអាងទន្លេ"*

- AusAID, យុទ្ធសាស្ត្រធនធានទឹកទន្លេមេគង្គ កញ្ញា ២០០៧[7]

*"យើងមិនបានបង្កើតអង្គការ ធ្វើជាអង្គការហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍទេ។ យើងមានមុខងារក្នុងការគាំទ្រដល់ការអភិវឌ្ឍក្នុងអាងទន្លេ។ យើងគ្មានមុខងារប្រតិបត្តិទេ តែយើងមានមុខងារជាអ្នកសម្របសម្រួល"*

-នាយកប្រតិបត្តិនៃ MRCS កិច្ចសម្ភាសន៍ជាមួយ IPS ឧសភា ២០០៨[8]

*"ឥឡូវនេះគឺដល់ពេលដែលត្រូវពិនិត្យឡើងវិញនូវមុខងាររបស់MRC ដើម្បីធានាថា MRC កំពុងធ្វើការក្នុងលក្ខណៈមួយដែលផ្តល់ផលប្រយោជន៍តាមវត្ថុបំណងមួយ ពោលគឺអង្គការគ្រប់គ្រងអាងទន្លេប្រកបដោយវិទ្យាសាស្ត្រដូចដែលបានបង្កើតឡើងមក។ ជំហានដំបូង និងសំខាន់សម្រាប់ MRC គឺថា ត្រូវផ្សព្វផ្សាយជាសាធារណៈឲ្យទំនប់ទាំងអស់ផ្អាកដំណើរការរហូតដល់មានភស្តុតាងជាវិទ្យាសាស្ត្រស្តីពីផលប៉ះពាល់ត្រួតគ្នា និងដាច់ដោយឡែក បង្កដោយការអភិវឌ្ឍទំនប់ ត្រូវបានដឹងឮដល់សាធារណៈ ហើយគ្រប់ភាគីពាក់ព័ន្ធ រួមទាំងការឯកភាពជាសាធារណៈ ត្រូវបានធ្វើឡើងល្អបំផុត"*

- ពំនោលរបស់ បណ្តាញប្រជាជនថៃសម្រាប់ទន្លេមេគង្គ និងសម្ព័ន្ធទន្លេកម្ពុជា កញ្ញា ២០០៨[9]

ខណៈដែល MRC ជាអង្គការ "ត្រូវបានអភិបាល" ជាជាងអង្គការ "អភិបាល" នេះជាអ្វីដែលមិនត្រូវបានយល់ពីសំណាក់ក្រុមសង្គមស៊ីវិលក្នុងតំបន់ ក្រុមនេះតែងតែអញ្ជើញ MRC - និងជាពិសេសលេខាធិការ - មកធ្វើអន្តរាគមន៍តាមតែសិទ្ធិដែលមានក្នុងការដោះស្រាយកង្វល់ ឬការកើតទុក្ខមិនសុខចិត្តដែលកើតឡើងដោយសារការអភិវឌ្ឍបង្កឲ្យមានផលប៉ះពាល់ឆ្លងកាត់ព្រំដែន។

ប្រហាក់ប្រហែលគ្នានេះដែរ អ្នកផ្តល់ជំនួយដែលបានផ្តល់ថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ឲ្យ MRC តាំងពីឆ្នាំ ១៩៩៥ បានផ្តល់ថវិកាទាំងនោះ ក៏ព្រោះតែសង្ឃឹមថា MRC នឹងមានអំណាចបានពីឆន្ទៈនយោបាយនៃប្រទេសជាសមាជិកក្នុងការគាំទ្រដំណើរការសម្រេចចិត្តដោយប្រកាន់យកប្រយោជន៍សាធារណៈដ៏ទូលំទូលាយ និងប្រយោជន៍ប្រព័ន្ធទន្លេ ពោលគឺលើសពីការបង្រួមចំណាប់អារម្មណ៍មកត្រឹមប្រទេសមួយវិញ។

ខណៈដែលមានការជជែកយ៉ាងក្តៅគគុកជុំវិញអំពី MRC ថាជាអង្គការបញ្ញាត្តិ ទល់នឹងមុខងារសម្រួលដល់វិនិយោគទុន គេមិនទាន់ឃើញមានយោបល់ទំទាស់ជុំវិញការធ្វើឲ្យ MRC ជាអង្គការប្រកបដោយចំណេះដឹងដែលផ្តល់ចំណេះដឹងវិទ្យាសាស្ត្រគ្មានលំអៀងសម្រាប់ជំនួយដល់ដំណើរការសម្រេចចិត្ត និងផែនការក្នុងអាងទន្លេទេ។ ផែនការយុទ្ធសាស្ត្ររបស់ MRC ឆ្នាំ២០០៦-២០១០ ផ្តល់យោបល់ថា "MRC ត្រូវចូលរួមយ៉ាងសកម្ម និងប្រកបដោយចក្ខុវិស័យក្នុងគម្រោងជាតិធំៗ" និងថា "ការបន្ថែមគុណតម្លៃ" របស់ខ្លួនក្នុងមុខងារនេះ គឺចំណេះដឹង និងឧបករណ៍វាយតម្លៃ[10]។ ចំណាប់អារម្មណ៍ គឺត្រូវបានផ្តោតលើ BDPថាជាឧបករណ៍សំខាន់មួយដែល MRC អាចធានាថា ការអភិវឌ្ឍទាំងឡាយក្នុងតំបន់អាងទន្លេ គឺមានការសហការគ្នាយ៉ាងល្អ ដោយមានមូលដ្ឋានលើវិធីសាស្ត្ររួមបញ្ចូលគ្នានៃធនធានទឹក និងការគ្រប់គ្រង (IWRM)។

ចំណាប់អារម្មណ៍លើ MRC ថាជាអង្គការផ្តល់ចំណេះដឹង នាំមកនូវសំណួរសំខាន់ៗមួយចំនួន ទាក់ទងនឹងដំណើរការនៃការបង្កើតចំណេះដឹង និងការទទួលបាន និងការប្រើប្រាស់នៃចំណេះដឹងទាំងនេះក្នុងដំណើរការសម្រេចចិត្ត។ បញ្ហាទាំងនេះ គឺចោតឡើងចំពោះទំនប់ដែលស្នើឡើងតាមដងទន្លេ។

**MRC ជា/អាច...**

- ជាអង្គការអន្តររដ្ឋាភិបាល ដែលមានម្ចាស់ និងអភិបាលដោយឆន្ទៈនៃប្រទេសជាសមាជិកទាំងបួន។
- អាចមានសមត្ថភាពក្នុងការបង្កើតចំណេះដឹងដែលអាចយកមកប្រើដើម្បីវាយតម្លៃគម្រោងមួយៗក្នុងបរិបទអាងទន្លេទាំងមូល។

**MRC មិនមែនជា/មិនអាច...**

- មិនមែនជាអង្គការមានអំណាចលើប្រទេសណាមួយជាមួយនឹងអំណាចបញ្ញាត្តិដែលខ្លួនមានទេ។
- មិនមែនជាអង្គការដែលអាចធ្វើការសម្រេចចិត្ត ឬធ្វើអន្តរាគមន៍ជាមួយនឹងសិទ្ធិដែលខ្លួនមានទេ។
- មិនអាចទទួលយកគណនេយ្យភាពពីសាធារណៈជនដ៏ទូលំទូលាយបានទេ។

**ចំនុចមិនច្បាស់លាស់**

- អាចឲ្យមានការចូលរួម និងទទួលយកគណនេយ្យភាពពីសំណាក់សាធារណៈជនមួយចំនួន។
- មានមុខងារជាអង្គការសកម្មមុនក្នុងការផ្តល់ចំណេះដឹងពីអាងទន្លេ។
- មានការឆ្លើយតបនឹងសំណូមពរដែលចង់បានចំណេះដឹងពីសាធារណៈជន។
- សមត្ថភាពក្នុងការជូនដំណឹង ឬជះឥទ្ធិពលលើការសម្រេចចិត្តក្នុងការអភិវឌ្ឍក្នុងតំបន់អាង។

**ទំនប់តាមដងទន្លេ និងមុខងាររបស់ MRC**

ដោយមានសំណួរលើកឡើងពីអ្នកផ្ដល់ជំនួយ និងក្រុមសង្គមស៊ីវិលអំពីមុខងាររបស់ MRC ពាក់ព័ន្ធនឹងទំនប់តាមដងទន្លេ នាពេលថ្មីនេះ MRC បានខិតខំបំភ្លឺពីមុខងាររបស់ខ្លួន និងផ្ដួចផ្ដើម ឬវិធីឆ្លើយតបភ្លាមនូវសកម្មភាពមួយចំនួនដែលផ្ដោតលើទំនប់តាមដងទន្លេ។ ដូចដែលនាយកប្រតិបត្តិនៃលេខាធិការ MRC ធ្វើការកត់សម្គាល់កាលពីខែមិថុនា ឆ្នាំ២០០៨ថា "គ្រប់ការងាររបស់យើងទាំងអស់ គឺមានការជំរុញដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងឡាយដែលលើកឡើងពីទំនប់តាមដងទន្លេ" [11]។ មុខងារ MRC ដែលបានលើកមកនិយាយទាក់ទងនឹងទំនប់តាមដងទន្លេក្នុងពេលនោះមានដូចជា[12] ៖

## ក. ការវាយតម្លៃលើអាងទាំងមូលចំពោះទំនប់តាមដងទន្លេ

កាលពីខែថ្មីៗនេះ MRC បានផ្ដួចផ្ដើមការសិក្សាមួយចំនួនដើម្បីវាយតម្លៃពីសក្ដានុពលដែលពាក់ព័ន្ធពីទំនប់តាមដងទន្លេលើ (ក្នុងចំណោមបញ្ហាផ្សេងៗទៀត) មច្ឆជាតិ កករ និងធារទឹកហូរ ដែលនឹងត្រូវយកមកដាក់បញ្ចូលក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ (SEA) ចំពោះទំនប់[13]។ សកម្មភាពទាំងនេះ ជា "វិធីឆ្លើយតបភ្លាមៗ" ដូច្នេះ អាចឲ្យគេផ្ដល់នូវក្របខ័ណ្ឌមួយ "ដែលក្នុងក្របខ័ណ្ឌនេះ នឹងធ្វើការពិនិត្យវាយ តម្លៃលើគម្រោងមួយៗ ស្របគ្នានឹងគម្រោងនេះស្នើឡើង និងពេលដែលគម្រោងនេះបង្កើតឡើងមុនពេលធ្វើការប្រឹក្សាយោបល់" [14] ។ ដូចបានលើកឡើងដោយ នាយកប្រតិបត្តិរបស់ MRCS ក្នុងឱកាសជាច្រើនថា អាទិភាពនេះបើតាមការយល់ឃើញរបស់ MRC គឺដាក់ព័ត៌មាន និងការវិភាគទាំងនេះលើតុ ជូន "អ្នកសម្រេចចិត្ត"[15]។

*បញ្ហា និងសំណួរសំខាន់ៗ*

- ខណៈដែលមានចំណេះដឹងជាគុណតម្លៃនៃ MRC កង្វល់ក៏កើតមានឡើងជុំវិញតម្លាភាពចំពោះដំណើរការបង្កើតចំណេះដឹង និងការទទួលបានចំណេះដឹងទាំងនោះ ហើយក្នុងនេះក៏មានពាក់ព័ន្ធនឹងភាពជឿជាក់បាន ក្នុងនាមជាអង្គការមួយដែលផ្ដល់នូវដំបូន្មានវិទ្យាសាស្ត្រមិនលំអៀង។ ដូចមានក្នុងការពិនិត្យវាយតម្លៃឯករាជ្យមួយរបស់ MRCS និង NMCs បានលើកឡើងថា "MRCS កំពុងត្រូវបានគេដឹងថាជា (ក្នុងចំណោមអង្គការសង្គមស៊ីវិល អង្គការវិទ្យាសាស្ត្រ) ស្ថាប័នមួយដែលនឹងមិនផ្ដល់ព័ត៌មានដែលបង្ហាញពីវិបត្តិជាអវិជ្ជមានចំពោះបរិស្ថាន និងសង្គមបង្កដោយគម្រោងអភិវឌ្ឍទេ។ នេះជាការគំរាមកំហែងមួយចំពោះភាពជឿជាក់លើអង្គការនេះ"[16]។
- ការពិនិត្យវាយតម្លៃដោយឯករាជ្យមួយចំពោះ MRC ក៏បានលើកឡើងថា ការផ្សាយគោលនយោបាយចេញជាសាធារណៈ គឺកំពុងតែដាក់បញ្ជូនឲ្យគណៈកម្មការចម្រុះ។ យ៉ាងណាក៏ដោយ ស្ថានភាពបច្ចុប្បន្ន ឬខ្លឹមសារនៃគោលនយោបាយនេះគឺមិនទាន់ផ្សព្វផ្សាយជាសាធារណៈនៅឡើយទេ[17]។
- នៅមានសំណួរបន្ថែមទៀតពីរបៀប និងថាតើចំណេះដឹងដែលបង្កើតឡើងដោយ MRC នឹងប្រើសម្រាប់ជាព័ត៌មានសម្រាប់ការសម្រេចចិត្តឬទេ ដោយហេតុថា គ្មានទំនាក់ទំនងណាមួយរវាងកម្មវិធី MRC និងប្រព័ន្ធផែនការជាតិ[18]។ ដូចលើកឡើងក្នុងផែនការយុទ្ធសាស្ត្ររបស់ MRC "ការសិក្សា និងការងារស្រាវជ្រាវ មិនថាធ្វើល្អបានប៉ុណ្ណាទេ នឹងគ្មានផលប្រយោជន៍ទេ ប្រសិនបើការសិក្សា និងការស្រាវជ្រាវទាំងនោះមិនត្រូវបានប្រើប្រាស់ក្នុងផែនការអភិវឌ្ឍ" [19]។ ស្រដៀងគ្នានេះដែរ ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវារីអគ្គីសនីឆ្នាំ២០០១ MRC ទទួលស្គាល់ថាការនៅមានកម្រិតនៃកិច្ច EIA និង SEA គឺដោយសារ "កង្វះខាតនៃទំនាក់ទំនងជាផ្លូវការជាមួយនឹងតួនាទីជាអ្នកសម្រេចចិត្ត តាមផ្លូវច្បាប់ និងសេដ្ឋកិច្ច" និងថា "គុណតម្លៃនៃកិច្ចការទាំងនោះ គឺពឹងផ្អែកលើឆន្ទៈរបស់អ្នកសម្រេចចិត្តធំៗ (ដូចជា អាជ្ញាធមិនយោបាយជាតិ និងស្ថាប័នផ្ដល់ជំនួយ និងហិរញ្ញវត្ថុអន្តរជាតិ) ដែលទទួលយក និងយកមកពិចារណាចំពោះសេចក្ដីសន្និដ្ឋាន និងអនុសាសន៍ក្នុងរបាយការណ៍ EIA"[20]។

## ខ. ការផ្តល់ជំនួយបច្ចេកទេសតាមសំណូមពរលើគម្រោងមួយៗ

ក្នុងមាត្រា ៣០ខ មុខងាររបស់លេខាធិការគឺ "ផ្តល់ការគ្រប់គ្រងបច្ចេកទេស និងហិរញ្ញវត្ថុ និងផ្តល់ជំនួយបច្ចេកទេសតាមសំណូមពរពីក្រុមប្រឹក្សា និងគណៈកម្មការចម្រុះ"។ ក្នុងឆ្នាំ២០០៧ រដ្ឋាភិបាលឡាវ ពោលគឺរដ្ឋបាលធនធានទឹក និងបរិស្ថាន ស្នើលេខាធិការឲ្យពិនិត្យវាយតម្លៃលើពង្រាង EIA ដែលរៀបចំសម្រាប់គម្រោង ដូន សំហុង របស់ក្រុមហ៊ុនឯកជនមួយ។ ជាការឆ្លើយតបនឹងសំណូមពរដោយអង្គការសង្គមស៊ីវិលចំពោះសាធារណៈឲ្យបញ្ចេញរបាយការណ៍ នាយកប្រតិបត្តិ MRCS លើកឡើងថា "ករណីបែបនេះ យើងត្រូវការស្វែងរកការសហការពីសំណាក់ភ្នាក់ងារមានសមត្ថកិច្ចដើម្បីបញ្ចេញរបាយការណ៍របស់យើង។ យ៉ាងណាក៏ដោយ ជាការមួយមិនសមស្របទេក្នុងការបញ្ចេញរបាយការណ៍ រហូតដល់សមាជិកប្រទេសផ្សេងទៀតមានឱកាសពិចារណាលើកិច្ចការទាំងនេះយ៉ាងលម្អិត"[21]។

*បញ្ហា និងសំណួរសំខាន់ៗ ៖*

- ការសិក្សា ឬជំនួយបច្ចេកទេសលើគម្រោងណាមួយត្រូវបានសំណូមពរពីប្រទេសជាសមាជិក។ បច្ចុប្បន្ននេះ គឺគ្មានយន្តការណាមួយដែលប្រទេសដែលគ្មានបន្ទុកអាចស្នើសុំព័ត៌មាន ឬការសិក្សារបស់គម្រោងពិសេសណាមួយដោយផ្ទាល់ពីMRCS ទេ។ សំណើបែបនេះ គឺត្រូវធ្វើឡើងតាមរយៈប្រទេសជាសមាជិក (មានន័យថា NMCs)។
- ជាគោលការណ៍ អារម្មណ៍របស់សហគមន៍ គឺត្រូវបានពាំនាំយកដោយអ្នកតំណាងពី NMCs តាមរូបភាពជាក់ស្តែង ពេលមានសហគមន៍មួយមានកង្វល់អំពី ឬបានរងផលប៉ះពាល់ពី គម្រោងអភិវឌ្ឍ វាជាការលំបាកណាស់សម្រាប់សហគមន៍នោះ ក្នុងការនាំយកកង្វល់តាមរយៈរចនាសម្ព័ន្ធរដ្ឋបាល។ តាមរយៈករណីទំនប់យាលីនៅទន្លេសេសាន គឺគ្មានការធានាណាមួយដែល NMCs នឹងទទួលយកករណីកើតទុកមិនសុខចិត្តរបស់សហគមន៍ទៅឲ្យ MRC ក្នុងករណីផលប៉ះពាល់ឆ្លងព្រំដែនទេ ក្នុងនោះរួមមានទាំងសំណូមពរឲ្យមានការសិក្សាពីផលប៉ះពាល់ទៀតផង។
- MRCS ធ្លាប់ធ្វើការវាយតម្លៃសេដ្ឋកិច្ចម្តងស្តីពីសក្តានុពលនៃការបាត់បង់មច្ឆជាតិ ដែលបណ្តាលមកពីសំណើសង់ទំនប់ដូន សំហុង ដែល (នេះតាមចំណេះដឹងរបស់អ្នកនិពន្ធ) មិនត្រូវបានស្នើឡើងជាផ្លូវការដោយប្រទេសជាសមាជិកទេ។ ដូច្នេះ ទំហំដែលលេខាធិការអាចវាយតម្លៃប្រកបដោយសកម្មមុនចំពោះគម្រោងមួយៗនោះ គឺនៅតែមិនច្បាស់លាស់ដដែល។

## គ. ការគ្រប់គ្រងនីតិវិធីសម្រាប់ជាការជូនដំណឹង ការផ្តល់ប្រឹក្សាយោបល់ និងកិច្ចព្រមព្រៀងមុន (PNPCA)

មាត្រា៥នៃកិច្ចព្រមព្រៀងទន្លេមេគង្គ និងនីតិវិធីដែលពាក់ព័ន្ធ សម្រាប់ការជូនដំណឹង ការផ្តល់ប្រឹក្សាយោបល់ និងកិច្ចព្រមព្រៀងមុន (PNPCA) បញ្ជាក់ថាការប្រើប្រាស់ទឹកក្នុងអាងក្នុងប្រទេសមួយតាមដងទន្លេមេគង្គនាពេលរដូវប្រាំង នឹងស្ថិតក្នុងការព្រមព្រៀងពីគណៈកម្មការចម្រុះ។ នេះមានន័យថា រាល់ទំនប់ដែលស្នើសុំសាងសង់តាមដងទន្លេ គឺតម្រូវឲ្យជូនដំណឹង និងប្រឹក្សាយោបល់ជាមុន និងចុងក្រោយគឺត្រូវទទួលបានការយល់ព្រមពីគណៈកម្មការចម្រុះ។

យោងតាមកិច្ចព្រមព្រៀង ប្រឹក្សាយោបល់មុនមានន័យថា "ជូនដំណឹងមុន ដោយទុកឲ្យមានពេលគ្រប់គ្រាន់ ថែមទាំងទិន្នន័យ និងព័ត៌មានជូនដល់គណៈកម្មការចម្រុះ" ហើយគណៈកម្មការនេះ គឺគ្មានសិទ្ធបដិសេធទេ។ បើតាម PNPCA រយៈពេលសម្រាប់ប្រឹក្សាយោបល់មុនគឺ៦ខែចាប់ពីថ្ងៃទទួលឯកសារពាក់ព័ន្ធជាផ្លូវការ ហើយគណៈកម្មការចម្រុះ អាចនឹងពន្យាពេលក្នុងការធ្វើការសម្រេចចិត្ត។

រហូតដល់សព្វថ្ងៃនេះ គ្មានការជូនដំណឹងស្តីពីសំណើសង់ទំនប់តាមដងទន្លេជាផ្លូវការណាមួយត្រូវបានធ្វើឡើងដោយប្រទេសជាសមាជិកទេ[22]។ យ៉ាងណាក៏ដោយ កាលពីខែមិថុនា ឆ្នាំ២០០៨ គណៈកម្មការទន្លេមេគង្គជាតិឡាវ បានផ្តល់ដំណឹងក្រៅផ្លូវការស្តីផែនការសង់ទំនប់៨កន្លែងលើដងទន្លេមេគង្គនៅប្រទេសឡាវ និងតាមព្រំប្រទល់ឡាវ-ថៃ។

*បញ្ហា និងសំណួរសំខាន់ៗ*

- ការអភិបាលលើនីតិវិធីជូនដំណឹងទាំងអស់ គឺជាគោលការណ៍ទូទៅដែលស្តីអំពីភាពទាន់ពេលវេលា និងស្មោះត្រង់ និងប្រកបដោយសហប្រតិបត្តិការណ៍។ យ៉ាងណាក៏ដោយ គ្មានកន្លែងណាមួយក្នុងនីតិវិធីដែលពន្យល់ពី "ការជូនដំណឹងតាមពេលវេលា" ឬ "ការប្រឹក្សាយោបល់" ទេ។ PNPCA ធ្វើការកត់សម្គាល់ថា ការប្រឹក្សាយោបល់មុនត្រូវបានធ្វើឡើងមុនពេលអនុវត្តគម្រោង និងថា ការសិក្សាក្នុងកម្រិតណាមួយនឹងត្រូវបានធ្វើឡើងដោយមានការជូនដំណឹងផងដែរ។ ដោយមានភាពមិនច្បាស់លាស់នេះ ការសុំបកស្រាយបំភ្លឺលើរបៀបនៃនីតិវិធីសម្រាប់ជូនដំណឹង ការប្រឹក្សាយោបល់ និងកិច្ចព្រមព្រៀងមុនដែលយកមកប្រើទាក់ទងនឹងការធ្វើទំនប់តាមដងទន្លេនេះ គឺត្រូវបានស្នើសុំដោយសង្គមស៊ីវិល និងអ្នកផ្តល់ជំនួយ[23]។
- ក្នុងនីតិវិធី គឺមិនបានតម្រូវឲ្យមានការពង្រីកការជូនដំណឹង និងការប្រឹក្សាយោបល់រហូតដល់អ្នកដែលពាក់ព័ន្ធដែលហួសពីប្រទេសជាសមាជិកទេ រួមទាំងសហគមន៍ដែលអាចនឹងរងផលប៉ះពាល់។

## ឃ. សម្របសម្រួលកិច្ចពិភាក្សា

បច្ចុប្បន្ននេះ MRC បានពន្លេចពីមុខងារដែលខ្លួនអាចធ្វើបានក្នុងការសម្របសម្រួលកិច្ចពិភាក្សាក្នុងចំណោមពេលខុសគ្នា ចំណាប់អារម្មណ៍ប្រកួតប្រជែងគ្នា និងខុសគ្នា និងបង្កបរិយាកាសពិភាក្សាដែលប្រកបដោយចំណេះដឹងទាក់ទងនឹងការអភិវឌ្ឍក្នុងអាងទន្លេ រួមទាំងទំបន់តាមដងទន្លេផងដែរ។ យោងតាមគេហទំព័ររបស់ MRC សកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងឡាយនៃកម្មវិធីវារីអគ្គីសនី នឹងរៀបចំឡើងដើម្បីសម្របសម្រួលកិច្ចពិភាក្សានៅកម្រិតផ្សេង និងរវាងការចាប់អារម្មណ៍ពីភាគីផ្សេងៗ។ សកម្មភាពដែលត្រូវបានដឹងរហូតដល់បច្ចុប្បន្ននេះ រួមមានការសម្របសម្រួលដល់ការរាយការណ៍សង្ខេបជូនក្រសួងចម្រុះក្នុងប្រទេសជាសមាជិកនីមួយៗ ដើម្បីទ្រទ្រង់ដល់ការពិភាក្សានិងការផ្សព្វផ្សាយពីលទ្ធផលដែលពាក់ព័ន្ធនឹងកម្មវិធីវារីអគ្គីសនី ការពិភាក្សាជាមួយអ្នកវិនិយោគទុន និងអ្នកផ្តល់ហិរញ្ញវត្ថុ បន្តកិច្ចពិភាក្សាជាមួយចិន និងផ្តល់ប្រឹក្សាយោបល់ជាមួយអ្នកដែលពាក់ព័ន្ធច្រើនទៀត។

តាមការដកស្រង់ពី BDP និងកម្មវិធីវារីអគ្គីសនីដែលបានផ្តល់ប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធក្នុងតំបន់ នាយកប្រតិបត្តិMRC បានអះអាងថា "ផែនការការងាររបស់ MRC សម្រាប់កម្មវិធីផ្សេងៗ គឺកំពុងមានការកើនឡើងនូវកិច្ចសហការក្នុងការបកស្រាយយ៉ាងទូលំទូលាយពីសំណាក់អ្នកចូលរួមដែលពាក់ព័ន្ធ ពោលគឺហួសពីការចូលរួមពីសំណាក់ភ្នាក់ងាររដ្ឋាភិបាល ដែលរួមមានសង្គមស៊ីវិល និងវិស័យឯកជន" [24]។

*បញ្ហា និងសំណួរសំខាន់ៗ ៖*

- សិក្ខាសាលាពហុអ្នកពាក់ព័ន្ធថ្នាក់តំបន់ គឺគ្មានអ្វីអាចជំនួសបានទេពាក់ព័ន្ធការចូលរួមរយៈពេលវែង និងអ្នកចូលរួមដែលប្រកបដោយអត្ថន័យពីសំណាក់ប្រទេសដែលមិនទទួលបន្ទុក។ វេទិកាថ្នាក់តំបន់នេះ គឺមិនទាន់បានរាប់បញ្ចូលអ្នកចូលរួមមកពីសហគមន៍ដែលអាចមានសក្តានុពលពីផលប៉ះពាល់ទេ។
- នានាភាពនៃចំណាប់អារម្មណ៍ចំពោះទឹក និងការគ្រប់គ្រងអាងទន្លេ គឺមិនបានបង្ហាញតាមរយៈ NMCs ទេ។ ទោះបីថា MRC គឺត្រូវបានដឹកមុខដោយផលប្រយោជន៍នៃប្រទេសជាសមាជិកក្តី សមត្ថភាពរបស់ MRC ក្នុងការឆ្លើយតបនឹងកង្វល់ដែលលើកឡើងដោយអ្នកទទួលបន្ទុកផ្សេងទៀតគឺនៅមានកម្រិត។
- ផែនការយុទ្ធសាស្ត្រ (២០០៦-២០១០) បានដាក់ចំណាប់អារម្មណ៍ចំពោះភាពចាំបាច់នៃការចូលរួមពីសាធារណៈជនក្នុងការធានាឲ្យបាននូវជោគជ័យរបស់ IWRM ក្នុងអាងទន្លេមេគង្គ។ យ៉ាងណាក៏ដោយ ការប្តេជ្ញាចិត្ត និងយុទ្ធសាស្ត្រក្នុងការឲ្យសង្គមស៊ីវិលចូលរួមគឺនៅតែមានការខ្វះខាត។
- សេចក្តីប្រាថ្នារបស់ MRC ឲ្យក្លាយជាអង្គការផ្តល់ចំណេះដឹងគ្មានលំអៀង នឹងមានការរាំងស្ទះដោយសារការកំហិតរបស់អ្នកទទួលបន្ទុកផ្សេងៗ ក្នុងការផ្តល់ និងទទួលព័ត៌មាន។

## ឯកសារយោង

---

[1] Agreement on the Cooperation for the Sustainable Development of the Mekong River Basin, 5 April 1995, Mekong River Commission. http://www.mrcmekong.org/agreement_95/agreement_95.htm

[2] Jeremy Bird, MRCS CEO, Remarks to Informal Donor Meeting: Vision for the Next Three Years, 20 June 2008. http://www.mrcmekong.org/MRC_news/speeches/ceo-speech-IDM-20Jun08.htm

[3] Nguyen Hong Toan, Secretary-General of VNMC and JC Member for Vietnam, in the Donor Consultative Group Meeting in Chiang Rai on 1 December 2005, in Hirsch, P. et al. (2006) *National interests and transboundary water governance in the Mekong*, Australian Mekong Resource Centre, School of Geosciences, University of Sydney in collaboration with Danida, p. 96. Available at http://www.mekong.es.usyd.edu.au/projects/mekong_water_governance2.htm

[4] World Bank & Asian Development Bank (2006) *WB/ADB Joint Working Paper on Future Directions For Water Resources Management In The Mekong River Basin: Mekong Water Resources Assistance Strategy (MWRAS*), June (Draft), p. 18.

[5] Donor Group Statement, 10th Meeting of the MRC-Donor Consultative Group, Chiang Rai, Thailand, 1 December 2005.

[6] This Statement was supported at the 12th Development Partner Consultative Group held on 15 November 2007 in Siem Reap, Cambodia by the following development partners: Asian Development Bank, Australia, Finland, France, Germany, Japan, Netherlands, Sweden, EU Commission, USA, World Bank.

[7] AusAID (2007) *The Greater Mekong Subregion: Australia's Strategy to Promote Integration and Cooperation 2007-2011*, September 2007, p. 25.

[8] Nette, A. Mekong Commission Fends Off Credibility Charges, *Inter Press Service*, 11 May 2008. http://www.ipsnews.net/news.asp?idnews=42321

[9] Statement Questioning the MRC's "Sustainable hydropower development," 24 September 2008. http://terraper.org/what_new_view.php?id=44

[10] Mekong River Commission, Strategic Plan 2006-2010, p.12

[11] Op. cit. 2

[12] For example, see Jeremy Bird CEO of MRCS, Introductory Speech, 7 April 2008, Vientiane, Lao PDR; Hydropower in the Context of Basin-wide Water Resources Planning, Speech by Jeremy Bird at *Regional Multi-Stakeholder Consultation on the MRC Hydropower Programme*, Vientiane, Lao PDR, 25-27 September 2008.

[13] Jeremy Bird, MRCS CEO, Speech at *Regional Multi-Stakeholder Consultation on the MRC Hydropower Programme*, Vientiane, Lao PDR, 25-27 September 2008. http://www.mrcmekong.org/MRC_news/speeches/hydropower-Basin-wide-context.htm

[14] Bird, J. (2008) Integrated Water Resources Management in a rapidly-growth private sector development context: the Mekong Basin. Presentation at the *World Water Week, Stockholm Asia Day: Theme 5 - Promoting Effective Basin*

*Management*, 19 August 2008.
http://www.mrcmekong.org/MRC_news/CEO%20MRCS%20speech%20WWW%20Stockholm%2008.pdf

[15] For example, see Bird, J. CEO of MRCS, A Responsible Approach to Dam Building, 25 September 2008; Op. cit. 7.

[16] Mekong River Commission, *Independent Organisational, Financial and Institutional Review of the Mekong River Commission Secretariat and the National Mekong Committees*, Final Report, January 2007, p. 20. http://www.mrcmekong.org/download/free_download/Financial_and_Institutional_Review.pdf

[17] ibid., pp.19-20.

[18] ibid., pp.13-14; AusAID (2007) *The Greater Mekong Subregion: Australia's Strategy to Promote Integration and Cooperation 2007-2011*, September 2007, Annex 3 Mekong Water Resource Strategy 2007-2011, pp. 20-30; Hirsch, P. et al. (2006) *National interests and transboundary water governance in the Mekong*, Australian Mekong Resource Centre, School of Geosciences, University of Sydney in collaboration with Danida; Op. cit. 2.

[19] Op. cit. 9, p.10.

[20] Mekong River Commission (2001) MRC Hydropower Development Strategy, October 2001, Phnom Penh, p. 33.

[21] Jeremy Bird, MRCS CEO, Statement in response to letter from TERRA dated 27 March 2008, 11 April 2008, p. 2. http://www.mrcmekong.org/MRC_news/speeches/MRCS-CEO-Responses-TERRA.pdf

[22] Radosevich, G. E., International Water Law Advisor (2008) Experience from the Procedures for Notification, Prior Consultation and Agreement, Presented at the *Regional Multi-Stakeholder Consultation of the MRC Hydropower Programme*, 25-27 September 2008 in Vientiane, Lao PDR. http://www.mrcmekong.org/download/programmes/hydropower/presentations/MRC%20HP%20Consult%20VTE%20908%20gr2.pdf

[23] Op. cit. 6

[24] Op. cit. 8

### លំដាប់ព្រឹតិបត្រទន្លេមេគង្គរបស់ AMRC

ព្រឹតិបត្រនេះ គឺមានលេខរៀងទី១០ក្នុងចំណោមលំដាប់ប័ណ្ណព័ត៌មានដែលត្រូវបានបោះពុម្ពដោយមជ្ឈមណ្ឌលធនធានទន្លេមេគង្គអូស្ត្រាលី (AMRC) សាកល វិទ្យាល័យស៊ីដនី ដែលប្រើសម្រាប់និស្សិត សាស្ត្រចារ្យ និងអ្នកផ្សេងទៀតដែលចាប់អារម្មណ៍ក្នុងតំបន់ទន្លេមេគង្គ។

AMRC ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ដើម្បីពង្រីកការស្រាវជ្រាវ ពិភាក្សា និងជជែកដេញដោលលើបញ្ហាអភិវឌ្ឍន៍ និងបរិស្ថានក្នុងតំបន់ទន្លេមេគង្គ។ AMRC ជាកន្លែងទំនាក់ទំនងសម្រាប់ព័ត៌មាន កិច្ចពិភាក្សា និងបង្កើតសកម្មភាពក្នុងការគ្រប់គ្រងដំណើរការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាព និងសមភាពសម្រាប់តំបន់ទន្លេមេគង្គ។

ប្រសិនបើលោកអ្នកចង់ធ្វើវិចារណ៍លើការបោះពុម្ពផ្សាយនេះ ឬក៏ចង់ចូលរួមក្នុងបញ្ជីទទួលព្រឹត្តិបត្រសង្ខេបនេះទៅថ្ងៃអនាគត សូមទំនាក់ទំនងមក ៖

Australian Mekong Resource Centre
C/- School of Geosciences (F09)
University of Sydney
NSW 2006 Australia
Tel: +61-2-9351-7796
Fax: +61-2-9351-8627
mekong@mail.usyd.edu.au
http://www.mekong.es.usyd.edu.au/

ព្រឹត្តិបត្រសង្ខេបនេះ រៀបចំឡើងដោយ Natalia Scurrah និង Gary Lee ដោយមានការឧបត្ថម្ភពីអង្គការ Oxfam អូស្ត្រាលី និងគណនេយ្យអនុស្សាវរីយ៍របស់ Charlie Pahlman ។